វិទ្យាស្ថានសភាកម្ពុជា
PARLIAMENTARY INSTITUTE OF CAMBODIA
STRENGTHENING PARLIAMENTARY CAPACITY

# ព្រឹត្តប័ត្រព័ត៌មានសង្ខេប

**សប្តាហ៍ដែលបញ្ចប់**
**ថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៨**

---

ចំណុចសំខាន់ៗ អំពីព័ត៌មានសេដ្ឋកិច្ច និងការអភិវឌ្ឍសារពើពន្ធនៅក្នុងបណ្តាប្រទេសជាសមាជិកអាស៊ាន និងនៅប្រទេសផ្សេងៗទៀតនៅក្នុងសប្តាហ៍នេះ គឺៈ

- ការដាក់ពន្ធរបស់អាមេរិកទៅលើចិននឹងបង្វែរការផលិតកង់មកធ្វើនៅប្រទេសកម្ពុជាវិញក្នុងឆ្នាំ២០១៩
- ការបង្កើតការងារតាមរយៈសេដ្ឋកិច្ចដែលប្រើប្រាស់ប្រព័ន្ធអ៊ិនធ័រណិត ត្រូវបានគេរំពឹងថានឹងកើនឡើងបីដងនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ក្នុងរយៈពេល៧ឆ្នាំខាងមុខ
- ខណៈដែលវិបត្តិសេដ្ឋកិច្ចកាន់តែមានឱកាសកើតឡើងខ្ពស់ ធនាគារកណ្តាលរបស់អាមេរិកនឹងមានការតម្លើងទៅលើអត្រាការប្រាក់តិចតួចជាងមុន

*ព្រឹត្តប័ត្រសង្ខេបព័ត៌មាននេះ គឺជាព្រឹត្តិប័ត្រប្រចាំសប្តាហ៍ដែលរៀបចំឡើងដើម្បីតាមដានព័ត៌មានអំពីការអភិវឌ្ឍសេដ្ឋកិច្ច និងសារពើពន្ធថ្មីៗ នៅក្នុងប្រទេសកម្ពុជា និងដៃគូពាណិជ្ជកម្មនានា។ ឯកសារនេះត្រូវបានធ្វើឡើងដោយក្រុមការងារ បណ្តុះបណ្តាលសមត្ថភាពការវិភាគសារពើពន្ធរបស់វិទ្យាស្ថានសភាកម្ពុជា ក្នុងគោលបំណងពង្រឹងជំនាញនៃការធ្វើឯកសារ និងការស្រាវជ្រាវរបស់ខ្លួន។ ការងារនេះត្រូវបានព្យាយាមធ្វើឡើងដើម្បីធានាថាការវិភាគ និងអត្ថន័យ ដែលបានផ្តល់នៅក្នុងឯកសារនេះ មានគុណភាពខ្ពស់។ ទោះជាយ៉ាងណាក៏ដោយ សូមអ្នកអានចាត់ទុកឯកសារនេះជាផ្នែកមួយនៃលំហាត់អនុវត្តនៅក្នុងកំឡុងពេលនៃការបណ្តុះបណ្តាល។ យើងមិនអាចធានាថាឯកសារនេះល្អឥតខ្ចោះនោះទេ។*

## ព័ត៌មាន និងទិន្នន័យអំពីប្រទេសកម្ពុជា

### ការដាក់ពន្ធរបស់អាមេរិកទៅលើចិននឹងបង្វែរការផលិតកង់មកធ្វើនៅប្រទេសកម្ពុជាវិញក្នុងឆ្នាំ២០១៩

ការផលិត និងការនាំចេញកង់ពីប្រទេសកម្ពុជាទៅកាន់អាមេរិកត្រូវបានរំពឹងថានឹងមានការកើនឡើង បន្ទាប់ពីអាមេរិកបានដាក់បន្ទុកពន្ធលើការនាំចូលពីប្រទេសចិន។ ការដាក់ពន្ធនេះត្រូវបានកំណត់ចំនួន១០% ហើយនឹងកើនដល់២៥%នៅក្នុងខែមករា ឆ្នាំ២០១៩។

ក្រុមហ៊ុនធំៗចំនួនពីរបាន[ប្រកាស]រួចជាស្រេចថាមានផែនការរើការផលិតរបស់ខ្លួនទៅប្រទេសកម្ពុជាក្នុងឆ្នាំ២០១៩ ព្រោះការយកពន្ធនាំចូលពីកម្ពុជានៅមានអត្រាទាប ឬមិនមានបន្ទុកពន្ធ។

កាលពីឆ្នាំមុន ការនាំចេញកង់ពីកម្ពុជាទៅអាមេរិកមានចំនួនគិតជាទឹកប្រាក់ប្រមាណ២៤លានដុល្លារអាមេរិក ចិតក្នុងលំដាប់ទីបីបន្ទាប់ពីចិន (៨៧៤ លានដុល្លារអាមេរិក) និងតៃវ៉ាន់ (៣៩០ លានដុល្លារអាមេរិក)។

### តារាងប្រចាំសប្តាហ៍៖ ចំណូលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

ចំណូលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិបានកើនឡើងពី ១ ៣៧២ ប៊ីលានរៀលនៅក្នុងឆ្នាំ២០១៥ ទៅ ២ ២០០ប៊ីលានរៀលក្នុងឆ្នាំ២០១៩ក្នុងកំរិតព្យាករណ៍ ដែលកំណើនប្រចាំឆ្នាំជាមធ្យមគឺប្រមាណ ១៣,៥%។ កំណើននេះគឺលើសកំណើននៃផ.ស.ស. ដែលចំណូលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិបានកើនពី ១,៩%ដល់ ២% នៃ ផ.ស.ស.។

ការបែងចែកចំណូលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិសម្រាប់រដ្ឋបាលរាជធានី ខេត្តមានកម្រិតថេរ ស្មើនឹងប្រមាណជា៦៥%ជាមធ្យមចាប់ពីឆ្នាំ២០១៥ ដល់ឆ្នាំ២០១៩ ប៉ុន្តែត្រូវបានព្យាករណ៍ថានឹង

កើនដល់៦៧% នៅឆ្នាំ២០១៩។ រីឯចំណូលដែលបែងចែកទៅអោយរដ្ឋបាលឃុំ សង្កាត់មានប្រហែល២៦%នៃចំណូលសរុបរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលអាចនឹងធ្លាក់ចុះក្រោម២៤%នៅក្នុងឆ្នាំ២០១៩។ ចំណែកការបែងចែកចំណូលសំរាប់រដ្ឋបាលស្រុកក្រុងត្រូវបានព្យាករណ៍ថាប្រហាក់ប្រហែលឆ្នាំមុនៗដែរ គឺប្រមាណជា៩%។

### ចំណូលរដ្ឋបាលថ្នាក់ក្រោមជាតិទៅតាមចំណែក ពីឆ្នាំ២០១៥ ទៅឆ្នាំ២០១៩




ប្រភព៖ ច្បាប់ស្តីពីការទូទាត់ថវិកាជាតិឆ្នាំ២០១៥-២០១៧ និងច្បាប់ស្តីពីការគ្រប់គ្រងថវិកាជាតិសម្រាប់ឆ្នាំ២០១៨-២០១៩

## ព័ត៌មាន និងទិន្នន័យរបស់បណ្តាប្រទេសនៅក្នុងអាស៊ាន និងដៃគូពាណិជ្ជកម្មដទៃទៀត

### ការបង្កើតការងារតាមរយៈសេដ្ឋកិច្ចដែលប្រើប្រាស់ប្រព័ន្ធអ៊ិនធឺណិត ត្រូវបានគេរំពឹងថានឹងកើនឡើងបីដងនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ក្នុងរយៈពេល៧ឆ្នាំខាងមុខ

យោងតាមការសិក្សាថ្មីមួយ របស់Google និងTemasek បានឲ្យដឹងថា សេដ្ឋកិច្ចតាមប្រព័ន្ធអ៊ីនធឺណិតនឹងបង្កើតការងារពេញម៉ោងចំនួន១,៧លាន នៅក្នុងតំបន់អាស៊ីអាគ្នេយ៍ក្នុងឆ្នាំ២០២៥ ពោលគឺកើនឡើងបីដងច្រើនជាងឆ្នាំ២០១៨។ ការបង្កើតការងារនេះ គឺដោយសារតែការកើនឡើងយ៉ាងឆាប់រហ័សក្នុងវិស័យ ដូចជា៖ ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក សេវាកម្មដឹកជញ្ជូនអ្នកដំណើរតាមកម្មវិធីក្នុងប្រព័ន្ធអ៊ិនធឺណេត (ដូចជា Uber, Lyft,...) ការធ្វើដំណើរ បណ្តាញផ្សព្វផ្សាយ និងការដឹកជញ្ជូនអាហារតាមប្រព័ន្ធអនឡាញ ក៏ដូចជាការទិញនូវបទចម្រៀង និងវីដេអូផ្សេងៗតាមតម្រូវការ។

កំណើនការងារក្នុងវិស័យនេះ នឹងបង្កើតចំនួនការងារចាប់ពី៤លានរហូតដល់១២លានក្នុងរយៈពេល៧ឆ្នាំទៅមុខ។ ការសិក្សាក៏បានព្យាករណ៍ដែរថា តម្លៃជាទឹកប្រាក់នៃសេដ្ឋកិច្ចតាមប្រព័ន្ធអ៊ីនធឺណិតនឹងកើនដល់២៤០ប៊ីលានដុល្លារ ត្រឹមឆ្នាំ២០២៥។

ការសិក្សានេះធ្វើឡើងតែក្នុង០៦ប្រទេស នៅក្នុងអាស៊ីអាគ្នេយ៍ប៉ុណ្ណោះ គឺប្រទេសឥណ្ឌូនេស៊ី ម៉ាឡេស៊ី ហ្វីលីពីន សិង្ហបុរី ថៃ និងវៀតណាម។

## សេដ្ឋកិច្ចសហរដ្ឋអាមេរិក និងទុនបម្រុងសហព័ន្ធ

### ខណៈដែលវិបត្តិសេដ្ឋកិច្ចកាន់តែមានសន្ទុះ ធនាគារកណ្តាលរបស់សហរដ្ឋអាមេរិកដំឡើងអត្រាការប្រាក់តិចជាងមុន

យោងតាមការស្ទង់មតិមួយរបស់សារព័ត៌មាន Reuters កាលពីសប្តាហ៍មុន សេដ្ឋវិទូនៅតែរំពឹងថា ធនាគារកណ្តាលរបស់សហរដ្ឋអាមេរិកនឹងដំឡើងអត្រាការប្រាក់សារជាថ្មីម្តងទៀតសម្រាប់ខែក្រោយ និងបីដងនៅឆ្នាំក្រោយ។ ទោះបីជាយ៉ាងណាក៏ដោយ សេដ្ឋវិទូបានគូសបញ្ជាក់នូវហានិភ័យធំៗមួយចំនួនដែលអាចធ្វើអោយការតម្លើងអត្រាការប្រាក់មានភាពយឺតយ៉ាវ ខណៈដែលវិបត្តិសេដ្ឋកិច្ចនៅសហរដ្ឋអាមេរិកក្នុងអំឡុងពេលពីរឆ្នាំទៀតអាចនឹងបន្តកើនឡើង (ទោះបីជាមានកម្រិតទាបក៏ដោយ)។

ឱកាសនៃការរីករាលដាលវិបត្តិសេដ្ឋកិច្ចនៅអាមេរិកក្នុងរយៈពេលពីរឆ្នាំទៀត អាចនឹងកើនពី៣០%ទៅ៣៥%។ កំណើន ផ.ស.ស. របស់អាមេរិក ត្រូវបានព្យាករណ៍ថានឹងមានការធ្លាក់ចុះមកត្រឹម២% ទៅ២,៥%នៅក្នុងឆ្នាំ២០១៩ និងដល់១,៨%នៅពាក់កណ្តាលឆ្នាំ២០២០ ដែលប្រហែលជាពាក់កណ្តាលនៃកំនើនបច្ចុប្បន្ន។

## ព័ត៌មានសម្រាប់សប្តាហ៍បន្ទាប់

ទិន្នន័យសម្រាប់សប្តាហ៍ខាងមុខនេះរួមមាន៖ តុល្យភាពនៃថវិកាជាតិរបស់ហ្វីលីពីន អត្រាអតិផរណានៅវៀតណាម និងអត្រាអ្នកអត់ការងារធ្វើនៅប្រទេសថៃ។

ខាងក្រោមគឺជាប្រតិទិនពេញលេញនៃការចេញនូវទិន្នន័យ និងការអភិវឌ្ឍ ដែលក្រុម FACT នឹងបន្តតាមដាននៅសប្តាហ៍ក្រោយ៖

<u>ថ្ងៃច័ន្ទ ទី២៦ ខែវិច្ឆិកា</u>

- តុល្យភាពនៃថវិកាជាតិរបស់ហ្វីលីពីន សម្រាប់ខែតុលា
- ផលិតកម្មឧស្សាហកម្មនៅប្រទេសសឹង្ហបុរី សម្រាប់ខែតុលា
- តុល្យភាពនៃជញ្ជីងពាណិជ្ជកម្មរបស់ហុងកុង សម្រាប់ខែតុលា

<u>ថ្ងៃអង្គារ ទី២៧ ខែវិច្ឆិកា</u>

- ទំនុកចិត្តរបស់អ្នកប្រើប្រាស់នៅកូរ៉េខាងត្បូង សម្រាប់ខែវិច្ឆិកា
- ប្រាក់ចំណេញផ្នែកឧស្សាហកម្មរបស់ប្រទេសចិន សម្រាប់ខែតុលា
- ផលិតកម្មឧស្សាហកម្មរបស់ប្រទេសថៃ សម្រាប់ខែតុលា

<u>ថ្ងៃពុធ ទី២៨ ខែវិច្ឆិកា</u>

- ទំនុកចិត្តលើវិស័យពាណិជ្ជកម្មនៅកូរ៉េខាងត្បូង សម្រាប់ខែវិច្ឆិកា
- អត្រាអតិផរណានៅប្រទេសវៀតណាម សម្រាប់ខែវិច្ឆិកា
- តុល្យភាពនៃជញ្ជីងពាណិជ្ជកម្មរបស់ប្រ៊ុយណេ សម្រាប់ខែកញ្ញា
- ការវិនិយោគផ្ទាល់ពីបរទេសនៅវៀតណាម សម្រាប់ខែវិច្ឆិកា

<u>ថ្ងៃព្រហស្បតិ៍ ទី២៩ ខែវិច្ឆិកា</u>

- ទិន្នន័យលក់រាយនៅជប៉ុន សម្រាប់ខែតុលា
- សន្ទស្សន៍តម្លៃសម្រាប់អ្នកផលិតនៅហ្វីលីពីន សម្រាប់ខែតុលា
- តុល្យភាពនៃជញ្ជីងពាណិជ្ជកម្មរបស់វៀតណាម សម្រាប់ខែវិច្ឆិកា
- ផលិតកម្មឧស្សាហកម្មរបស់វៀតណាម សម្រាប់ខែវិច្ឆិកា
- ទិន្នន័យលក់រាយរបស់វៀតណាម សម្រាប់ខែវិច្ឆិកា
- សន្ទស្សន៍តម្លៃសម្រាប់អ្នកផលិតនៅសឹង្ហបុរី សម្រាប់ខែតុលា

<u>ថ្ងៃសុក្រ ទី៣០ ខែវិច្ឆិកា</u>

- ផលិតកម្មឧស្សាហកម្មនៅកូរ៉េខាងត្បូង សម្រាប់ខែតុលា
- ទិន្នន័យលក់រាយរបស់កូរ៉េខាងត្បូង សម្រាប់ខែតុលា
- អត្រាអ្នកអត់ការងារធ្វើនៅជប៉ុន សម្រាប់ខែតុលា
- ផលិតកម្មឧស្សាហកម្មនៅជប៉ុន សម្រាប់ខែតុលា
- សេចក្តីសម្រេចស្តីពីអត្រាការប្រាក់នៅកូរ៉េខាងត្បូង
- អត្រាអ្នកអត់ការងារធ្វើនៅប្រទេសថៃ សម្រាប់ខែតុលា
- ទិន្នន័យលក់រាយរបស់ថៃ សម្រាប់ខែកញ្ញា
- ផ.ស.ស. របស់តៃវ៉ាន់នៅក្នុងត្រីមាសទី៣ ឆ្នាំ២០១៨